# លើកកម្ពស់ជីវភាព និងវប្បធម៌របស់ ជនជាតិដើមភាគតិចនៅកម្ពុជា

## ការិយាល័យOHCHR បាននិងកំពុងគាំទ្រដល់សហគមន៍ជនជាតិដើមភាគតិច ក្នុងកិច្ចខិតខំស្វះស្វែងរបស់ពួកគេ ទាមទារឲ្យមានសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី ដែលនឹងធានាដល់ការរស់រានមានជីវិតរបស់ពួកគេ និងសម្រាប់ជាផលប្រយោជន៍ដល់មនុស្សជំនាន់ក្រោយ



លោក ឈឿន ឆន តំណាងជនជាតិដើមភាគតិច កំពុងរៀបចំធ្វើបទបង្ហាញរបស់លោក មុនពេលជួបប្រជុំជាមួយគណៈប្រតិភូនៃអង្គការ ជីអាយ ហ្សេដ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅចុងខែមិថុនា ឆ្នាំ២០១៥

ឈឿត ឆន តំណាងមួយរូបនៃសហគមន៍ជនជាតិដើមភាគតិចព័រ នៅភូមិភ្នំរ៉ៃ ខេត្តបាត់ដំបង មានទំនាក់ទំនងយ៉ាងពិសេស ជាមួយនឹងដីរបស់គាត់ ជីភាពរស់នៅ វប្បធម៌របស់គាត់ ដូច្នេះហើយ ជីវិតរស់នៅរបស់គាត់គឺពឹងអាស្រ័យលើដីនោះ។ ដើម្បីធានាដល់ការរស់រានមានជីវិតរបស់ពួកគាត់ ជនជាតិដើមភាគតិច ត្រូវមានសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី ដែលនៅកម្ពុជា ពួកគាត់អាចទទួលបានក្នុងរូបភាពជាប័ណ្ណកម្មសិទ្ធិដីសមូហភាព។ ទោះជាយ៉ាងណាក៏ដោយ ប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះអាចនឹងសម្រេចទៅបាន ដោយត្រូវបំពេញដំណើរការដាក់ពាក្យសុំដែលមានលក្ខណៈស្មុគស្មាញ ដែលស្ទើរតែមិនអាចស្របទៅនឹងរបៀបដែលពួកគេបាន និងកំពុងរស់នៅអស់រយៈពេលរាប់រយឆ្នាំមកហើយនោះទេ។ ប៉ុន្តែ នេះមិនមែនជាឧបសគ្គតែមួយគត់របស់ពួកគេនោះឡើយ។ ធ្វើឲ្យបញ្ហាកាន់តែអាក្រក់ថែមទៀតនោះ គឺដីដូនតារបស់ពួកគេ ដែលជាញឹកញយជាផ្នែកមួយនៃសម្បទានដីសេដ្ឋកិច្ចដែលអាជ្ញាធរបានផ្តល់ទៅឲ្យក្រុមហ៊ុនជាតិ និងក្រុមហ៊ុនអន្តរជាតិ។ ដើម្បីជួយដល់ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ដោយសម្បទានដីដែលមានបញ្ហា ដែលធ្វើឲ្យពួកគេងាយរងគ្រោះដោយការរំលោភទន្ទ្រានយកដីធ្លី ការិយាល័យOHCHR បានប្រកាសបើកជាផ្លូវការនូវគំនិតផ្តួចផ្តើមពិសេស នៅក្នុងឆ្នាំ២០១១ ដើម្បីជួយពួកគេ ធ្វើការទាមទារនិងការពារសិទ្ធិដីធ្លីរបស់ខ្លួន។ ក្នុងគោលដៅនេះ ការិយាល័យOHCHR បានផ្តល់ការគាំទ្រផ្នែកច្បាប់ ហិរញ្ញវត្ថុ និងភស្តុភារដល់ភូមិចំនួនប្រាំពីរ ដែលមានសហគមន៍ជនជាតិដើមភាគតិចព្នង រស់នៅ នៅស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ជនជាតិដើមភាគតិចសួយ ចំនួនបីសហគមន៍ក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ និងជនជាតិដើមភាគតិចព័រចំនួនមួយសហគមន៍ នៅស្រុកសំឡូត ខេត្តបាត់ដំបង។ ក្រៅពីវគ្គបណ្តុះបណ្តាលផ្សេងៗ ដូចជា ស្តីពីដំណើរការដ៏ស្មុគ្រស្មាញដើម្បីឲ្យមានការទទួលស្គាល់ស្របច្បាប់ជាជនជាតិដើមភាគតិច ការគូសផែនទីដីរបស់ពួកគេ និងការដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព ដែលបានផ្តល់ដល់សហគមន៍ជនជាតិដើមភាគតិច អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងតំណាងអាជ្ញាធរមូលដ្ឋាន ការិយាល័យ OHCHR ក៏បានជួយឧបត្ថម្ភផងដែរដល់ជំហានផ្សេងៗនៃដំណើរការនេះ រាប់ទាំងការបំពេញនិងការដាក់ពាក្យសុំដែលចាំបាច់។

ចាប់តាំងពីបានប្រកាសបើកជាផ្លូវការនូវគំនិតផ្តួចផ្តើមនេះមក សហគមន៍ភាគច្រើន ដែលបានគាំទ្រដោយការិយាល័យ OHCHR បានបញ្ចប់ដោយជោគជ័យនូវដំណាក់កាលពីរ ក្នុងចំណោមដំណាក់កាលទាំងអស់ចំនួនបួន នៃដំណើរការដាក់ពាក្យសុំដែលមានរយៈពេលវែងសម្រាប់ប័ណ្ណកម្មសិទ្ធិដីសមូហភាព។ ដោយមានការប្រឈមនឹងកិច្ចអភិវឌ្ឍដីសម្បទានដ៏ឆាប់រហ័ស ដែលគំរាមគំហែងដល់ដំណើរការនេះ មនុស្សមួយក្រុម ដែលជាប្រជាពលរដ្ឋព័រនៅភាគពាយ័ព្យនៃខេត្តបាត់ដំបង បានទទួលដោយជោគជ័យផងដែរនូវវិធានការការពារជាបណ្តោះអាសន្នលើដីដូនតារបស់ពួកគេ នៅក្នុងឆ្នាំ២០១៤ ដែលបានអនុញ្ញាតឲ្យពួកគេបន្តទៅជំហានបន្ទាប់ក្នុងបរិយាកាសមួយដែលកាន់តែមានសុវត្ថិភាពថែមទៀត ដោយសារពួកគេបានទទួលភ្លើងខៀវ ដើម្បីចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់ខ្លួន នៅក្នុងឆ្នាំ២០១៥។

"ដោយសារតែមានការគាំទ្រពីការិយាល័យ OHCHR ក្នុងការធ្វើឲ្យអ្វីៗកើតមាន និងទទួលស្គាល់យើងជានីតិបុគ្គល ទើបសហគមន៍របស់ខ្ញុំអាចទទួលបានសិទ្ធិកាន់កាប់ដីធ្លីរបស់យើង ឬអភិរក្សប្រពៃណី និងវប្បធម៌របស់យើងបាន។ ដោយសារតែមានការគាំទ្ររបស់ការិយាល័យ OHCHR នេះហើយ យើងក៏អាចធ្វើការទាមទារបានបានមកវិញផងដែរនូវដីរបស់យើងដែលមានទំហំជាង ៧០០ ហិកតា ពីដីចម្ការ។"

ឈឿត ឆន តំណាងសហគមន៍ ភូមិរ៉ៃ ខេត្តបាត់ដំបង